**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**
**លេខ** :..............៣៣៨...........ក.ប/ស.ជ.ណ.ម.ណ

# សេចក្តីជូនដំណឹង
# ស្តីពី
# ការពន្យាពេលស្នើសុំប្រើប្រាស់ហត្ថពលកម្មបរទេសសម្រាប់ឆ្នាំ២០១៨

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចេញសេចក្តីជូនដំណឹងលេខ ២៧២ កប/ស.ជ.ណ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៧ កំណត់យកថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៧ ជាឱសានវាទក្នុងការស្នើសុំប្រើប្រាស់ហត្ថពលកម្មបរទេស (Quota) របស់សហគ្រាស គ្រឹះស្ថាននានាសម្រាប់ឆ្នាំ២០១៨។

ចំពោះករណីនេះក្រសួងបានពិនិត្យឃើញថា ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថានមួយចំនួន នៅបន្តដាក់ពាក្យស្នើសុំប្រើប្រាស់ហត្ថពលកម្មបរទេស (Quota) សម្រាប់ឆ្នាំ២០១៨ ដោយមានភាពយឺតយ៉ាវច្រើន។ ចំពោះស្ថានភាពបែបនេះ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជម្រាបដល់ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថានថា ក្រសួងបានពន្យាពេលសម្រាប់ការស្នើសុំប្រើប្រាស់ហត្ថពលកម្មបរទេស (Quota) សម្រាប់ឆ្នាំ២០១៨ រហូតដល់ដំណាច់**ខែមករា ឆ្នាំ២០១៨**។

អាស្រ័យហេតុដូចជម្រាបជូនខាងលើនេះ សូមម្ចាស់ ឬនាយកសហគ្រាសគ្រឹះស្ថានទាំងឡាយ ដែលមានសេចក្តីត្រូវការប្រើប្រាស់ហត្ថពលកម្មបរទេស ប្រញាប់លើកសំណើសុំការប្រើប្រាស់ហត្ថពលកម្មបរទេសសម្រាប់ឆ្នាំ២០១៨ តាមរយៈគេហទំព័រ www.fwcms.mlvt.gov.kh ឱ្យបានមុនដំណាច់**ខែមករា ឆ្នាំ២០១៨** ជាកំហិត។ ចំពោះការខកខានមិនបានស្នើសុំប្រើប្រាស់ហត្ថពលកម្មបរទេស (Quota) និងប្រើប្រាស់ជនបរទេសដោយខុសច្បាប់ ក្រសួងនឹងចាត់វិធានការដាក់ពិន័យតាមទោសប្បញ្ញត្តិក្នុងជំពូកទី១៦ នៃច្បាប់ស្តីពីការងារ។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សង្ឃឹមយ៉ាងមុតមាំថា ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថានទាំងអស់នឹងអនុវត្តតាមសេចក្តីជូនដំណឹងនេះដោយប្រសិទ្ធភាព។

ថ្ងៃព្រហស្បតិ៍ ៣កើត ខែមិគសិរ ឆ្នាំរកា នព្វស័ក ព.ស ២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ ១២ គ.ស ២០១៧
**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

**កន្លែងទទួល:**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រីប្រចាំការ
- ក្រសួងមហាផ្ទៃ
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
  "ដើម្បីជូនជ្រាប"
- គ្រប់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត
  "ដើម្បីផ្សព្វផ្សាយ និងអនុវត្ត"
- សមាគមនិយោជក "ដើម្បីជ្រាប និងអនុវត្ត"
- ឯកសារ-កាលប្បវត្តិ